57/6

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍បាត់ដំបង

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ ៤០៥

ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២

សាលដីកា

លេខៈ ៥១ (គ)

ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣

# តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍បាត់ដំបង

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស០១៥/០៧១៤/រកម/ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ និងព្រះរាជក្រឹត្យលេខ នស/រកត/០២២០/១៩៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ បានបើកសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាឧទ្ធរណ៍បាត់ដំបងនាថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ ដោយមានសមាសភាពដូចតទៅៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា

ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីពិភាក្សាដេញដោលលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៥ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ ដែលមានៈ

១-ឈ្មោះ [redacted] ស៊ីណា ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើតនៅភូមិ [redacted] ខេត្តកំពង់ចាម កាន់សាសនាព្រះពុទ្ធ មានទីលំនៅបច្ចុប្បន្នភូមិស្វាយ [redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) មេម៉ាយ មានកូន៣នាក់ ជានីតិជន កម្រិតវប្បធម៌មិនចេះអក្សរ ទោសពីមុន គ្មាន។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ១៤១៩ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២១។

57/5

**ជាប់ចោទពីបទ៖** ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ (កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច៦) នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១។

២.ឈ្មោះ [redacted] ផៃ ហៅ ថៃ ភេទប្រុស អាយុ៥៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើតនៅភូមិ [redacted] ខេត្តតាកែវ កាន់សាសនាព្រះពុទ្ធ មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (ស) ពោះម៉ាយ មានកូន៣នាក់ ជានីតិជន កម្រិតវប្បធម៌មិនចេះអក្សរទោសពីមុន មាន (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ:១៩១៨ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២១។

**ជាប់ចោទពីបទ៖** ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងមិនរាងចាល ក្នុងបទឧក្រិដ្ឋបន្ទាប់ពីការផ្ដន្ទាទោសបទមជ្ឈិម តាមបញ្ញត្តិមាត្រា៤០ (កថាខណ្ឌ៣ និងកថាខណ្ឌ៧ ចំណុច៤) នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា៨៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១។

-ដោយមានលោក [redacted] សិរីវុឌ្ឍី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ។

## អំពីអង្គហេតុ

## រឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង១៧និង០០នាទី នៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កម្លាំងសមត្ថកិច្ចបានធ្វើការបង្ក្រាបករណីគ្រឿងញៀនមួយ ដែលបង្កដោយឈ្មោះ [redacted] ស៊ីណា ភេទស្រី អាយុ៣៨ឆ្នាំ បានទិញគ្រឿងញៀនចំនួន១ថ្រុង ក្នុងតម្លៃ៦០ម៉ឺនរៀល ពីឈ្មោះ [redacted] ផៃ ហៅ ថៃ ភេទប្រុស អាយុ៥៩ឆ្នាំ ដើម្បីយកមកវែកលក់បន្ត។ ដោយគ្រឿងញៀនទាំងនេះ ឈ្មោះ [redacted] ផៃ ហៅ ថៃ បានទិញបន្តពីឈ្មោះ ម៉ៅ ភេទប្រុស ម្ដងៗចំនួន៥ខាំ ក្នុង១ខាំតម្លៃ៤០០$ ដើម្បីយកមកវែកលក់បន្តទៀត។ លុះនៅថ្ងៃកើតហេតុពេលកំពុងធ្វើសកម្មភាពក៏ត្រូវសមត្ថកិច្ចធ្វើការឃាត់ខ្លួននិងដកហូតបានថ្នាំញៀនសរុប៥៨៤,៨៧ក្រាម(ទាំង សំបក) នេះតែម្ដង។

**-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ: ៧២៦ "ខ" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានសេចក្ដីសម្រេចដូចតទៅ៖**

I.ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ភេទស្រី អាយុ៣៨ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល០៦(ប្រាំមួយ)ឆ្នាំ និងពិន័យជាប្រាក់កំណត់ចំនួន១០០០០០០០៛ (ដប់លានរៀល) ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០ (កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច៦) នៃច្បាប់ស្ដីពីការ ត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០២១ ។

II.ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ផៃ ហៅ ថៃ ភេទប្រុស អាយុ៥៩ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល២០(ម្ភៃ)ឆ្នាំ និងពិន័យជាប្រាក់កំណត់ចំនួន៤០០០០០០០៛(សែសិបលានរៀល) ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង មិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីការផ្ដន្ទាទោសបទមជ្ឈិម

តាមបញ្ញត្តិមាត្រា៤០ (កថាខណ្ឌ៣ និងកថាខណ្ឌ៧ ចំណុច៤) នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា៨៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១។

III.វត្ថុតាងរួមមាន៖

-គ្រឿងញៀនជាប្រភេទម្សៅក្រាមពណ៌សថ្លា ចំនួន១០,៩២ក្រាម និងគ្រឿងញៀនជាប្រភេទម្សៅក្រាមពណ៌សថ្លា ចំនួន៥២៥,១០ក្រាម ដែលនៅសល់ពីការដកសំណាក ។

-ទូរស័ព្ទដៃចាស់ចំនួន០២គ្រឿង,ជញ្ជីងសម្រាប់ថ្លឹងថ្នាំញៀនលក់ចំនួន២គ្រឿង និងថង់សម្រាប់វែកថ្នាំញៀនលក់មួយចំនួន។

**សាលក្រមនេះប្រកាសជាសាធារណៈនៅសាលាដំបូងខេត្តបាត់ដំបងនៅថ្ងៃអង្គារ ០៥កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ពស.២៥៦៦ ត្រូវនឹងថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២។**

សម្រេចសេចក្តីចំពោះមុខជនជាប់ចោទ បើកផ្លូវប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់។

-**បានឃើញ**: ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] **ស៊ីណា** ដែលបានសុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: **៧២៦ "ផ"** ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបាត់ដំបង **គ្រង់សេចក្តីសម្រេចទាំងមូល**។

-**បានឃើញ**: ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ផៃ ដែលបានសុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: **៧២៦ "ផ"** ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបាត់ដំបង **គ្រង់សេចក្តីសម្រេចទាំងមូល**។

-**បានឃើញ**: របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ។

-**បានឃើញ**: សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ ។

## **<u>នាពេលសវនាការ</u>**

-ជនជាប់ចោទឈ្មោះ [redacted] **ស៊ីណា** (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] **ផៃ ហៅ ថៃ** (វត្តមាន)

-លោក [redacted] **សិរីវុឌ្ឍី** មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ (វត្តមាន)

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះសង្ខេបរបាយការណ៍រឿង

-ជនជាប់ចោទឈ្មោះ [redacted] **ស៊ីណា** បានឆ្លើយថា ខ្លួនទទួលស្គាល់អង្គហេតុ តែសុំបន្ធូរបន្ថយទោស ព្រោះទោសច្រើនពេក។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនយូរហើយ ខ្លួនលក់ទើបតែលើកទីមួយទេ ខ្លួនប្រើប្រាស់ប្រហែលជាជាង១០ឆ្នាំហើយ មូលហេតុដែលខ្លួនលក់គ្រឿងញៀនព្រោះថាខ្លួនអត់មានលុយចាយ។

-ជនជាប់ចោទឈ្មោះ [redacted] **ផៃ ហៅ** ថៃ បានឆ្លើយថា ខ្លួនបានប្តឹងឧទ្ធរណ៍ព្រោះថានៅសាលាដំបូងខ្លួនឆ្លើយបិទបាំងចម្លើយ។ ខ្លួនទទួលស្គាល់អង្គហេតុតែស៊ីឈ្នួលគេទេ។ កាលមុនធ្លាប់ជាប់ពីរឆ្នាំ ខ្លួនទើបចេញពីពន្ធនាគារ ២ ឆ្នាំ។

-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ដោយសារតែសាលាដំបូងបានតែប្រែបទចោទប្រកាន់ តំណាងមហាអយ្យការយល់ឃើញថាការផ្តន្ទាទោសនេះសមរម្យហើយ ដូច្នេះតំណាងមហាអយ្យការស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់សាលក្រមសាលាដំបូងទុកជាបានការដដែល។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទបានសារភាព ហើយសាលាដំបូងបានកែប្រែបទចោទប្រកាន់ ហេតុនេះស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួន។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពររបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## **សាលាឧទ្ធរណ៍បាត់ដំបង**

## **យល់ឃើញថា**

១.ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍បាត់ដំបង ទទួលជំនុំជម្រះបានយោងតាមបញ្ញត្តិមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២.ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ផៃ ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍បាត់ដំបង ទទួលជំនុំជម្រះបានយោងតាមបញ្ញត្តិមាត្រា ៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម មាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣.ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា បានឆ្លើយថានៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ០២និង០០នាទី ខ្លួនបានតេទូរស័ព្ទទាក់ទងទិញថ្នាំញៀនពីឈ្មោះ [redacted] ផៃ ហៅ ថៃ ចំនួន០១ ផ្រុង ក្រោយមកឈ្មោះ [redacted] ផៃ បានណាត់ខ្លួនឱ្យទៅយកថ្នាំញៀនពីគាត់នៅតាមផ្លូវម្តុំបេីនឡាន ព្រៃវែង ស្ថិតនៅភូមិដូង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ឈ្មោះ [redacted] ផៃ បានយកថ្នាំញៀនមកឱ្យខ្លួនចំនួន០១ផ្រុង តម្លៃ៦០០០០ (ហុកសិបម៉ឺន)រៀល ហើយក៏ត្រូវសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង។

៤.ជនជាប់ចោទឈ្មោះ [redacted] ផៃ ហៅ ថៃ បានឆ្លើយថានៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ ខ្លួនបានតេទូរស័ព្ទទៅឈ្មោះ ម៉ៅ មិនស្គាល់នាមត្រកូល ភេទប្រុស មិនស្គាល់ផ្ទះ ដែលលេខទូរស័ព្ទរបស់ខ្លួនមានលេខ ០៩៧ ៨៦ ៩៨ ០១១ និងលេខទូរស័ព្ទរបស់ឈ្មោះ ម៉ៅ លេខ០៩៨ ៨៤ ១០ ៦២ ដើម្បីទាក់ទងទិញថ្នាំញៀនពីឈ្មោះ ម៉ៅ ក្រោយមកឈ្មោះ ម៉ៅ បានជិះម៉ូតូយកថ្នាំញៀនមកឱ្យខ្លួននៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង នៅតាមផ្លូវ នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោងប្រហែលជា២១និង០០នាទី ឈ្មោះម៉ៅ បានយកថ្នាំញៀនមកលក់ឱ្យខ្លួនចំនួន ០៥(ប្រាំ)ខាំ តម្លៃ០១(មួយ)ខាំ ៤០០(បួនរយ)ដុល្លា ក្រោយមកខ្លួនបានយកថ្នាំញៀននោះមកលាក់ទុកក្នុងបន្ទប់ជួលរបស់ខ្លួន ស្ថិតនៅភូមិគ្រាង ឃុំគ្រាង ស្រុកកំរៀង ខេត្តបាត់ដំបង ក្រោយមកខ្លួនបាន



Scanned with CamScanner

វលែកថ្នាំញៀននោះលក់ឱ្យឈ្មោះ លី ស៊ីណា ភេទស្រី បានចំនួន០២(ពីរ)លើក មួយលើកចំនួនមួយផ្ទុង តម្លៃ ៤៥០០០០ (សែសិបប្រាំម៉ឺន)រៀល ។ នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោងប្រហែលជា ១៧និង៣៥ នាទី ឈ្មោះ [redacted] ស៊ីណា បានតេទូរស័ព្ទមកឱ្យខ្លួនកម្មង់ទិញថ្នាំញៀនចំនួនកន្លះផ្ទុង តម្លៃ២០០០០០(ម្ភៃម៉ឺន) រៀល ក្រោយមកខ្លួនបានយកថ្នាំញៀនទៅឱ្យឈ្មោះ [redacted] ស៊ីណា នៅភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង តែត្រូវសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង ពេលនោះសមត្ថកិច្ចរកឃើញថ្នាំញៀនចំនួន០១(មួយ)ថង់ នៅក្នុងហោប៉ាវខាងស្តាំ និងបានធ្វើការឆែកឆេរនៅបន្ទប់ជួលរបស់ខ្លួនរកឃើញថ្នាំញៀនម៉ាទឹកកកចំនួន ៣(បី)ថង់ ថ្នាំញៀនយ៉ាម៉ាចំនួន០១គ្រាប់កន្លះ ពិតជារបស់ខ្លួនមែន។

៥.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ដែលបានទិញថ្នាំញៀនពីឈ្មោះ [redacted] ផៃ ហៅ ថៃ គឺជាអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ផៃ ហៅ ថៃ ដែលបានទិញថ្នាំញៀនពីឈ្មោះ ម៉ៅ និងបានលក់ថ្នាំញៀនឱ្យឈ្មោះ លី ស៊ីណា ហើយបានរក្សាទុកនូវថ្នាំញៀននៅបន្ទប់ជួលរបស់ខ្លួនដែលមានទីតាំងស្ថិតនៅភូមិគ្រាង ឃុំគ្រាង ស្រុកកំរៀង ខេត្តបាត់ដំបង គឺជាអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម ។

៦.មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ស៊ីណា ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០ (កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច៦) នៃច្បាប់ស្តីពីការ ត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០២១ និងឈ្មោះ [redacted] ផៃ ហៅ ថៃ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង មិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម តាមបញ្ញត្តិមាត្រា៤០ (កថាខណ្ឌ៣ និងកថាខណ្ឌ៧ ចំណុច៤) នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា៨៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១។

៧.តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង បានធ្វើសេចក្តីសន្និដ្ឋានសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បាត់ដំបង ពិនិត្យ ពិចារណា សម្រេចតាមនីតិវិធីច្បាប់។

៨.រឿងក្តីនេះត្រូវបានសាលាដំបូងខេត្តសៀមរាប លើកយកសំអាងហេតុមកបញ្ជាក់ត្រឹមត្រូវហើយ សាលាឧទ្ធរណ៍បាត់ដំបងឯកភាព ដោយពុំចាំបាច់លើកយកសំអាងហេតុដដែលនោះមកបញ្ជាក់សារជាថ្មីទៀតទេ ប៉ុន្តែជនជាប់ចោទ ក៏ដូចជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានសំណូមពរ សុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិនិត្យ ពិចារណា បន្ធូរបន្ថយទោសឱ្យដល់ជនជាប់ចោទព្រោះជនជាប់ចោទបានដឹងនូវកំហុសនឹងបានសារភាពនាពេលសវនាការ មានកូននៅតូចនៅក្នុងបន្ទុក និងជាស្ត្រីមេម៉ាយត្រូវទទួលរ៉ាប់រងចិញ្ចឹមកូន ហេតុនេះគប្បីក្រុមប្រឹក្សាជំនុំជម្រះ ពិចារណា លើសំណូមពរនេះ ដោយសម្រេចកែប្រែការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ឱ្យបានសមរម្យ។



Scanned with CamScanner

57

៩.សាលក្រមព្រហ្មទណ្ឌលេខៈ ៧២៦ “ជ” ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបាត់ដំបង សម្រេចត្រឹមត្រូវតាមច្បាប់ហើយ គប្បីសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បាត់ដំបង តម្កល់ទុកជាបានការដដែល លើកលែងតែចំណុច I.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ត្រូវសម្រេចកែប្រែដូចការយល់ឃើញខាងលើ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១.ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ទុកជាត្រឹមត្រូវតាមច្បាប់ ។

២.ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ផៃ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

៣.តម្កល់ សាលក្រមព្រហ្មទណ្ឌលេខៈ ៧២៦ “ជ” ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការ លើកលែងតែចំណុច I.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ភេទស្រី អាយុ៣៨ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈ ពេល០៦(ប្រាំមួយ)ឆ្នាំ និងពិន័យជាប្រាក់កំណត់ចំនួន១០,០០០,០០០រ (ដប់លានរៀល) ត្រូវកែប្រែមកជា ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ភេទស្រី អាយុ៣៨ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល០៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់កំណត់ចំនួន១០,០០០,០០០រ (ដប់លានរៀល) ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០ (កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច៦) នៃច្បាប់ស្តីពីការ ត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០២១ ។ ចំណុចក្រៅពីនេះរក្សាទុកជាបានការដដែល។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនាថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ និង ប្រកាសជាសាធារណៈថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទ ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជី** ហត្ថលេខាៈ [redacted]

**ចៅក្រមប្រឹក្សា** ហត្ថលេខាៈ [redacted], [redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** ហត្ថលេខាៈ [redacted]

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

បាត់ដំបង,ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner